ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមិថុនា និងទិសដៅការងារខែកក្កដា ឆ្នាំ២០២៥

នៅក្នុងខែមិថុនា ឆ្នាំ២០២៥ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

## I-លទ្ធផលការងារសម្រេចបានលើមុខងារទាំង៥

### ១-មុខងារនីតិកម្ម

- បានរៀបចំចាត់ចែង និងផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បំពេញមុខងារនីតិកម្ម៖
  - ❖ កិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៥ ចំនួន១លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ដើម្បីពិនិត្យសំណើរបស់គណៈកម្មការជំនាញ ដែលមានរបៀបវារៈ ដូចខាងក្រោម៖
    - ១- ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យបណ្តាក្រុមហ៊ុនវិនិយោគអភិវឌ្ឍថាមពលអគ្គិសនី ចំនួន២៤ច្បាប់ ទៅក្នុងរបៀបវារៈសម័យប្រជុំលើកទី៣ព្រឹទ្ធសភា នីតិកាលទី៥។
    - ២- ពិនិត្យ និងសម្រេចលើសំណើរបស់គណៈកម្មការផែនការ វិនិយោគ កសិកម្ម រុក្ខាប្រមាញ់ នេសាទ អភិវឌ្ឍន៍ជនបទ បរិស្ថាន ធនធានទឹក និងឧតុនិយម សុំដាក់សេចក្តីព្រាងច្បាប់ស្តីពី ជលផល ទៅក្នុងរបៀបវារៈសម័យប្រជុំលើកទី៣ព្រឹទ្ធសភា នីតិកាលទី៥។
    - ៣- ពិនិត្យ និងសម្រេចលើការបោះឆ្នោតជ្រើសរើសបំពេញសមាជិកគណៈកម្មការមហាផ្ទៃ ការពារជាតិ មុខងារសាធារណៈ និងកិច្ចការព្រំដែន និងគណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី ទៅក្នុងរបៀបវារៈសម័យប្រជុំលើកទី៣ព្រឹទ្ធសភា នីតិកាលទី៥ និង
    - ៤- កំណត់កាលបរិច្ឆេទ និងរបៀបវារៈ បន្តសម័យប្រជុំលើកទី៣ព្រឹទ្ធសភា នីតិកាលទី៥។

❖ បើកសម័យប្រជុំលើកទី៣ព្រឹទ្ធសភា នីតិកាលទី៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ដែលមានរបៀបវារៈដូចខាងក្រោម៖

១- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការជានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យបណ្តាក្រុមហ៊ុនវិនិយោគអភិវឌ្ឍថាមពលអគ្គិសនី ចំនួន២៤ច្បាប់។

២- ពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ជលផល និង

៣- បោះឆ្នោតជ្រើសរើសបំពេញសមាជិកគណៈកម្មការមហាផ្ទៃ ការពារជាតិ មុខងារសាធារណៈ និងកិច្ចការព្រំដែន និងគណៈកម្មការសុខាភិបាល សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងកិច្ចការនារី។

❖ សមាជរដ្ឋសភា និងព្រឹទ្ធសភា លើកទី១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាប្រធានសមាជរដ្ឋសភា និងព្រឹទ្ធសភា នៅវិមានរដ្ឋសភា។

❖ អញ្ជើញថ្លែងបិទសមាជរដ្ឋសភា និងព្រឹទ្ធសភា លើកទី១ នៅវិមានរដ្ឋសភា។

❖ ប្រជុំផ្ទៃក្នុងគណៈកម្មការ និងប្រជុំអន្តរគណៈកម្មការជាមួយតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ ចំនួន២៥ច្បាប់ និង

❖ ប្រជុំស្តីពី ការធ្វើវិសោធនកម្មច្បាប់បោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា។

## ២-មុខងារតំណាង

**- បានរៀបចំចាត់ចែង និងផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា៖**

**❖ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា៖**

- **សកម្មភាពចុះមូលដ្ឋាន៖**
  - បានអញ្ជើញជួបប្រជុំជាមួយមេបញ្ជាការអង្គភាពចំណុះទិសទី២ និងទិសទី៣ នៅទីបញ្ជាការស្រាលទិសទី៣ ក្រុងសំរោង ខេត្តឧត្តរមានជ័យ។
  - បានអញ្ជើញជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ស្រុក ក្រុង នៅខេត្តឧត្តរមានជ័យ ចំនួន២៤៨នាក់។
  - បានអញ្ជើញជួបប្រជុំជាមួយមេបញ្ជាការអង្គភាព និងយោធិនប្រចាំទិសទី១ នៅបញ្ជាការដ្ឋានអង្គរក្សជួរមុខទិសទី១ ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។
  - បានអញ្ជើញជួបសំណេះសំណាលសួរសុខទុក្ខជនភៀសខ្លួន នៅទីទួលសុវត្ថិភាព នៅវត្តពោធិ៍៥០០០ដើម ខេត្តព្រះវិហារ និង
  - បានអញ្ជើញជួបសំណេះសំណាលជាមួយសមាជិក-សមាជិកាក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ខេត្តព្រះវិហារ ចំនួន៤៦៤នាក់ នៅសាលាខេត្តព្រះវិហារ។
- **សកម្មភាពចូលរួមពិធីផ្សេងៗ៖**
  - បានអញ្ជើញដង្ហែ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា ស្តេចយាងជាព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់បំផុត

ក្នុងព្រះរាជពិធីទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោក ៥ មិថុនា ២០២៥ ក្រោមប្រធានបទ៖ "ប្រយុទ្ធប្រឆាំងការបំពុលដោយប្លាស្ទិក" នៅបរិវេណពហុកីឡដ្ឋានជាតិមរតកតេជោ រាជធានីភ្នំពេញ និង

- បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសព **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ម៉ុម ជឹមហ៊ុយ** ទីប្រឹក្សាសម្តេចតេជោប្រធានព្រឹទ្ធសភា និងជាអតីតសមាជិករាជរដ្ឋាភិបាល រដ្ឋសភា និងព្រឹទ្ធសភា នៅសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

❖ **ឯកឧត្តម អ៊ុច បូររិទ្ធ អនុប្រធានទី១ព្រឹទ្ធសភា៖**

- **សកម្មភាពចុះមូលដ្ឋាន៖**
  - បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីសម្ពោធឆ្លងឧបដ្ឋានសាលា និងសមិទ្ធផលនានា ប្រគេនដល់ព្រះសង្ឃ និងជូនពុទ្ធបរិស័ទចំណុះជើងវត្ត នៅក្នុងសីមាវត្តជ្រៃបិទមាស ខេត្តត្បូងឃ្មុំ។
  - បានអញ្ជើញចុះជួបសំណេះសំណាល សួរសុខទុក្ខ និងនាំយកថវិកា ស្បៀងអាហារ និងសម្ភារៈប្រើប្រាស់មួយចំនួនចែកជូនកងកម្លាំងជួរមុខ នៅកងពលតូចអន្តរាគមន៍លេខ៨ និងទីបញ្ជាការអង្គរក្ស (ទួល៩៥) ខេត្តព្រះវិហារ និង
  - បានអញ្ជើញគោរពវិញ្ញាក្ខន្ធសព **លោកអនុសេនីយ៍ត្រី សោ វុទ្ធី** មេបញ្ជាការកងអនុសេនាតូចស៊ើបការណ៍វរសេនាតូចលេខ៣៩២ នៅទីបញ្ជាការវរសេនាតូចអន្តរាគមន៍លេខ៣៩២ ក្នុងពេលបំពេញភារកិច្ចការពារជាតិមាតុភូមិ បូរណភាពទឹកដី និងអធិបតេយ្យ នៅខេត្តព្រះវិហារ។
- **សកម្មភាពចូលរួមពិធីផ្សេងៗ៖**
  - បានអញ្ជើញចូលរួមក្នុងព្រះរាជពិធីទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោក ៥ មិថុនា ២០២៥ ក្រោមប្រធានបទ៖ "ប្រយុទ្ធប្រឆាំងការបំពុលដោយប្លាស្ទិក" ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា នៅពហុកីឡដ្ឋានជាតិមរតកតេជោ រាជធានីភ្នំពេញ។
  - បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីប្រគល់-ទទួលម៉ាស៊ីនលាងឈាម និងបរិក្ខារពេទ្យ ដែលជាអំណោយដ៏ថ្លៃថ្លារបស់ក្រុមហ៊ុន Dongze Medical នៃសាធារណរដ្ឋប្រជាមានិតចិន ជូនក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។
  - បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីប្រគល់-ទទួលសម្ភារៈវេជ្ជសាស្ត្រ ឱសថ និងសម្ភារៈប្រើប្រាស់ប្រចាំថ្ងៃ ដែលជាជំនួយមនុស្សធម៌របស់មូលនិធិសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ ជូនដល់រដ្ឋបាលខេត្តកណ្តាល នៅសាលាខេត្តកណ្តាល។
  - បានអញ្ជើញចូលរួមក្នុងពិធីពិសាអាហារពេលល្ងាច រៀបចំដោយ **លោកជំទាវ តេអូ ឡា ចេង** ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋសិង្ហបុរី ប្រចាំព្រះរាជាណាចក្រកម្ពុជា និង

- បានអញ្ជើញចូលរួមជាមួយគណៈប្រតិភូព្រឹទ្ធសភា ដឹកនាំដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា អញ្ជើញគោរពវិញ្ញាណក្ខន្ធសព **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ម៉ុម ជឹមហ៊ុយ** ទីប្រឹក្សាសម្តេចតេជោប្រធានព្រឹទ្ធសភា និងជាអតីតសមាជិករាជរដ្ឋាភិបាល រដ្ឋសភា និងព្រឹទ្ធសភា នៅខណ្ឌសែនសុខ រាជធានីភ្នំពេញ។

❖ **ឯកឧត្តមបណ្ឌិត ឆន់ ទង្សនា អនុប្រធានទី២ព្រឹទ្ធសភា៖**

▪ **សកម្មភាពចូលរួមកិច្ចប្រជុំ៖**

- បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំជាមួយទីប្រឹក្សា ថ្នាក់ដឹកនាំ និងសមាជិកខុទ្ទកាល័យ ដើម្បីជំរុញការងារស្រាវជ្រាវលើប្រធានបទសំខាន់ៗដូចជា សេដ្ឋកិច្ចសាមគ្គី សេដ្ឋកិច្ចព្រំដែន អាហារ និងការអប់រំកុមារ ព្រមទាំងកំណត់របៀបរបបធ្វើការងារឱ្យមានប្រសិទ្ធភាព និងអាចរួមចំណែកដល់ស្ថិរភាពនយោបាយ កំណើនសេដ្ឋកិច្ច និងវឌ្ឍនភាពសង្គម នៅសាលពិសេស៣ វិមានព្រឹទ្ធសភា និង
- បានអញ្ជើញដឹកនាំកិច្ចប្រជុំជាមួយ ឯកឧត្តម លោកជំទាវ ជាប្រធានគណៈកម្មការទាំង១០ព្រឹទ្ធសភា ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ ក្រុមសមាជិកាព្រឹទ្ធសភា និងគណៈកម្មការក្រមសីលធម៌សភារបស់សមាជិកព្រឹទ្ធសភា ដើម្បីរៀបចំផែនការសកម្មភាពតាមមូលដ្ឋាន នៅចន្លោះសម័យប្រជុំលើកទី៣ និងលើកទី៤ នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។

▪ **សកម្មភាពចុះមូលដ្ឋាន៖**

- បានអញ្ជើញចូលរួមជាមួយគណៈប្រតិភូព្រឹទ្ធសភា ដឹកនាំដោយ **ឯកឧត្តម អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** អញ្ជើញចុះជួបសំណេះសំណាល សួរសុខទុក្ខ និងនាំយកថវិកា ស្បៀងអាហារ និងសម្ភារៈប្រើប្រាស់មួយចំនួនទៅចែកជូនដល់កងកម្លាំងជួរមុខនៅតាមបន្ទាត់ព្រំដែន នៅកងពលតូចអន្តរាគមន៍លេខ៨ ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ និង
- បានអញ្ជើញសួរសុខទុក្ខ និងនាំយកថវិកា ដែលបានមកពីការចូលរួមឧបត្ថម្ភពីថ្នាក់ដឹកនាំ សាស្ត្រាចារ្យ និងនិស្សិតនៃសាកលវិទ្យាល័យរដ្ឋ ចំនួន២០ រួមទាំងថវិកាផ្ទាល់របស់ឯកឧត្តមបណ្ឌិត និងលោកជំទាវ ដើម្បីជូនគ្រួសារសព **លោកព្រឹន្ទបាលឯក សួន រ៉ាន** នៅស្រុកជាំក្សាន្ត ខេត្តព្រះវិហារ។

▪ **សកម្មភាពចូលរួមពិធីផ្សេងៗ៖**

- បានអញ្ជើញចូលរួមក្នុងព្រះរាជពិធីទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោក ៥ មិថុនា ២០២៥ ក្រោមប្រធានបទ៖ "ប្រយុទ្ធប្រឆាំងការបំពុលដោយប្លាស្ទិក" ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា នៅពហុកីឡដ្ឋានជាតិមរតកតេជោ រាជធានីភ្នំពេញ។

- បានអញ្ជើញចូលរួមជាមួយគណៈប្រតិភូព្រឹទ្ធសភា ដឹកនាំដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា អញ្ជើញគោរពវិញ្ញាណក្ខន្ធសព **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ម៉ុម ជឹមហ៊ុយ** ទីប្រឹក្សាសម្តេចតេជោប្រធានព្រឹទ្ធសភា និងជាអតីតសមាជិករាជរដ្ឋាភិបាល រដ្ឋសភា និងព្រឹទ្ធសភា នៅខណ្ឌសែនសុខ រាជធានីភ្នំពេញ។
- បានអញ្ជើញជាអធិបតីក្នុងកម្មវិធីការដាក់ឱ្យប្រើប្រាស់បណ្ណាល័យ មេគង្គ-ឡានឆាង នៅក្នុងសាលាបឋមសិក្សាព្រែកលៀប ដោយមានការអញ្ជើញចូលរួមពី **ឯកឧត្តម វ៉ាង វិនពីន** ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប្រជាមានិតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា ឯកឧត្តម លោកជំទាវ សមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងភ្ញៀវកិត្តិយសជាតិ-អន្តរជាតិ នៅសង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។
- បានអញ្ជើញចូលរួមក្នុងកម្មវិធីជួបជុំអតីតនិស្សិតមកពីសាកលវិទ្យាល័យ Nagoya ប្រទេសជប៉ុន នៅសណ្ឋាគារ Fairfield by Marriott រាជធានីភ្នំពេញ។
- បានអញ្ជើញចូលរួមពិធីទិវាសហព័ន្ធរុស្ស៊ី នៅសណ្ឋាគារសូហ្វីតែលភ្នំពេញ ភូគីត្រា រាជធានីភ្នំពេញ និង
- បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសព **ឯកឧត្តម សុក ខា** អតីតអនុប្រធានគណៈកម្មាធិការជាតិ រៀបចំបុណ្យជាតិ-អន្តរជាតិ នៅខណ្ឌចំការមន រាជធានីភ្នំពេញ។

❖ **សមាជិក សមាជិកាព្រឹទ្ធសភាបាន៖**

- អញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោក ៥ មិថុនា ២០២៥ ក្រោមប្រធានបទ៖ "ប្រយុទ្ធប្រឆាំងការបំពុលដោយប្លាស្ទិក" ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅពហុកីឡដ្ឋានជាតិមរតកតេជោ រាជធានីភ្នំពេញ។
- អញ្ជើញចូលរួមអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា អនុញ្ញាតឱ្យប្រតិភូក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ដឹកនាំដោយ **លោកជំទាវកិត្តិបណ្ឌិត អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងជាប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ចូលជួបសម្តែងការគួរសម នៅវិមាន៧មករា រាជធានីភ្នំពេញ។
- អញ្ជើញចូលរួមអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ដឹកនាំគណៈប្រតិភូព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញគោរពវិញ្ញាណក្ខន្ធសព **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ម៉ុម ជឹមហ៊ុយ** ទីប្រឹក្សាសម្តេចតេជោប្រធានព្រឹទ្ធសភា និងជាអតីតសមាជិករាជរដ្ឋាភិបាល រដ្ឋសភា និងព្រឹទ្ធសភា នៅខណ្ឌសែនសុខ រាជធានីភ្នំពេញ។
- អញ្ជើញចូលរួមសិក្ខាសាលាស្តីពី លទ្ធផលនៃកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់កម្ពុជា និងសភាពការណ៍អន្តរជាតិ ក្រោមអធិបតីភាពរបស់ **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភា នៅវិមានរដ្ឋសភា។

- អញ្ជើញចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពី ការកំណត់លក្ខខណ្ឌនៃការប្រើប្រាស់ដី និងការគ្រប់គ្រងនគរូបនីយកម្ម និងសំណង់ក្នុងតំបន់រមណីយដ្ឋានបេតិកភណ្ឌពិភពលោក ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សាយ សំអាល់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅសណ្ឋាគារបាយ័នអេរ៉ា ខេត្តសៀមរាប។
- អញ្ជើញចូលរួមក្នុងពិធីប្រគល់-ទទួលសម្ភារៈវេជ្ជសាស្ត្រ ឱសថ និងសម្ភារៈប្រើប្រាស់ប្រចាំថ្ងៃ ដែលជាជំនួយមនុស្សធម៌របស់មូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ (Global Life Sharing) ជូនរដ្ឋបាលខេត្តកណ្តាល ក្រោមអធិបតីភាពរបស់ **ឯកឧត្តម អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា នៅសាលាខេត្តកណ្តាល។
- អញ្ជើញចូលរួមអម **ឯកឧត្តម អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា ក្នុងពិធីប្រគល់-ទទួល ម៉ាស៊ីនលាងឈាម និងបរិក្ខារពេទ្យ ជូនក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។
- អញ្ជើញចូលរួមទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សន្តិបណ្ឌិត នេត សាវឿន** ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកជាប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅពហុកីឡដ្ឋានជាតិអូឡាំពិក រាជធានីភ្នំពេញ។
- អញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាការងារ ដើម្បីត្រៀមរៀបចំសន្និបាតរបស់សមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ នៅសាលប្រជុំគណៈកម្មការទី៨ព្រឹទ្ធសភា។
- អញ្ជើញចូលរួមស្តាប់បទបង្ហាញស្តីពី ការស្រាវជ្រាវ អង្កេត និងវិភាគរបស់សមាគមសហគ្រិនស្ត្រីកម្ពុជាពាក់ព័ន្ធនឹងស្ត្រី ក្រោមអធិបតីភាព **លោកជំទាវ មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។
- អញ្ជើញផ្តល់បាឋកថាស្តីពី គោលនយោបាយការបរទេស និងវិស័យការទូតសភា នៅសាកលវិទ្យាល័យជាតិគ្រប់គ្រង។
- អញ្ជើញចូលរួមធ្វើបទបង្ហាញស្តីពី នយោបាយការទូតសភា និងរចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់ព្រឹទ្ធសភា និងចែករំលែកនូវបទពិសោធន៍ជូនសាស្ត្រាចារ្យ ព្រះសង្ឃ និងនិស្សិតនៃវិទ្យាស្ថានវ៉ាន់ដា និងសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ដែលបានមកបំពេញទស្សនកិច្ចសិក្សាឈ្វេងយល់អំពីព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា នៅវិមានព្រឹទ្ធសភា។
- អញ្ជើញចុះជួបសំណេះសំណាល សួរសុខទុក្ខ និងនាំយកជំនួយឧបត្ថម្ភ ជូនបងប្អូនវីរយុទ្ធជនជួរមុខការពារព្រំដែន នៅខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ។
- អញ្ជើញចូលរួមការធ្វើដំណើរថ្មើរជើង "Solidarity March" ដោយចេញដំណើរពីសាលមហោស្រពកោះពេជ្រ ឆ្ពោះទៅកាន់វិមានឯករាជ្យ។
- អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីផ្សេងៗ **ចំនួន២លើក** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី**នៃព្រះរាជាណាចក្រកម្ពុជា រួមមាន៖
  - ១/ ពិធីសម្ពោធអគារសិក្សា អគារទីចាត់ការ អគារសយនដ្ឋាន និងសមិទ្ធផលនានា នៅក្នុងខេត្តរតនគិរី និង
  - ២/ ពិធីអបអរសាទរ ការដំណើរការជាផ្លូវការ ១ឆ្នាំ របស់សមាគមសហព័ន្ធអ្នកវិនិយោគកម្ពុជា និងពិសាភោជនាហារសាមគ្គី ឆ្នាំ២០២៥ នៅរាជធានីភ្នំពេញ។

❖ ដោយឡែក សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល ប្រធានមណ្ឌលសុខភាព និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៥ នៅមូលដ្ឋាន ឈ្វេងយល់អំពីវឌ្ឍនភាពការងារ ការងារសន្តិសុខ សណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ពិនិត្យហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា **ចំនួន៦៥លើក** ព្រមទាំងបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធសមិទ្ធផលនានា និងពិធីផ្លូវការផ្សេងៗ **ចំនួន១៤២លើក**។

- **សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖**

❖ **ឯកឧត្តមអគ្គលេខាធិការ** និង**ឯកឧត្តមអគ្គលេខាធិការរង** បានអញ្ជើញចូលរួមសមាជរដ្ឋសភា និងព្រឹទ្ធសភា លើកទី១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាប្រធានសមាជរដ្ឋសភា និងព្រឹទ្ធសភា នៅវិមានរដ្ឋសភា។

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភាបាន៖

- អញ្ជើញចូលរួមធ្វើសន្និសីទសារព័ត៌មានរួម អំពីលទ្ធផលនៃកិច្ចប្រជុំសមាជរដ្ឋសភា និងព្រឹទ្ធសភា នៅវិមានរដ្ឋសភា។
- អញ្ជើញចូលរួមអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាជាតិដើម្បីស្ត្រី នៅវិមាន៧មករា និង
- អញ្ជើញចូលរួមអមដំណើរ **ឯកឧត្តម អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា ដឹកនាំគណៈប្រតិភូព្រឹទ្ធសភា អញ្ជើញគោរពវិញ្ញាណក្ខន្ធសព **លោកអនុសេនីយ៍ត្រី សោ វុទ្ធី** មេបញ្ជាការកងអនុសេនាតូចស៊ើបការណ៍វរសេនាតូចលេខ៣៩២ នៅទីបញ្ជាការវរសេនាតូចអន្តរាគមន៍លេខ៣៩២ ក្នុងពេលបំពេញភារកិច្ចការពារជាតិមាតុភូមិ នៅខេត្តព្រះវិហារ។

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា **ឯកឧត្តម ឈីវ យីស៊ាង** នាយកខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានអញ្ជើញនាំយកជង្វាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា ថ្វាយ **សម្តេចព្រះមហាក្សត្រីនរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងឱកាសចម្រើនព្រះជន្មាយុគម្រប់ ៨៩ព្រះវស្សា យាងចូល ៩០ព្រះវស្សា។

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា **ឯកឧត្តម ខេង សិទ្ធិគុណ** និង**ឯកឧត្តម អោក ប៉ូ៉** អគ្គលេខាធិការរងព្រឹទ្ធសភាបាន៖

- អញ្ជើញចូលរួមអមដំណើរ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយឧត្តមសេនីយ៍ផុតលេខផ្កាយមាស៥ និងជាប្រធានព្រឹទ្ធសភា អញ្ជើញសួរសុខទុក្ខកងទ័ព និងប្រជាពលរដ្ឋនៅខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារ។

- អញ្ជើញចូលរួមអមដំណើរ **ឯកឧត្តម អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា ដឹកនាំគណៈប្រតិភូព្រឹទ្ធសភា អញ្ជើញចុះជួបសំណេះសំណាល សួរសុខទុក្ខ និងនាំយកថវិកា ស្បៀងអាហារ និងសម្ភារៈប្រើប្រាស់មួយចំនួនទៅប្រគល់ជូនដល់កងកម្លាំងការពារព្រំដែន នៅកងពលតូចអន្តរាគមន៍លេខ៨ និងទីបញ្ជាការអង្គរក្ស (ទួល៩៥) ខេត្តព្រះវិហារ និង
- ដឹកនាំគណៈប្រតិភូអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញចុះសួរសុខទុក្ខ និងប្រគល់អំណោយឧបត្ថម្ភរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយឧត្តមសេនីយ៍ផុតលេខផ្កាយមាស៥ និងជាប្រធានព្រឹទ្ធសភា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា ជូនកងទ័ពជួរមុខ នៅកងពលធំអន្តរាគមន៍លេខ២ និងបានជួបសម្តែងការគួរសមជាមួយ **ឯកឧត្តមនាយឧត្តមសេនីយ៍កិត្តិសង្គហបណ្ឌិត ហ៊ីង ប៊ុនហៀង** អគ្គមេបញ្ជាការរងកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងអង្គរក្ស ព្រមទាំងបានជួបសំណេះសំណាលជាមួយកងកម្លាំងឈរជើង នៅប្រាសាទតាមាន់ ខេត្តឧត្តរមានជ័យ។

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា និង**ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភាបាន៖

- អញ្ជើញចូលរួមអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ដឹកនាំគណៈប្រតិភូព្រឹទ្ធសភា គោរពវិញ្ញាណក្ខន្ធសព **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ម៉ុម ជឹមហ៊ុយ** ទីប្រឹក្សាសម្តេចតេជោប្រធានព្រឹទ្ធសភា និងជាអតីតសមាជិករាជរដ្ឋាភិបាល រដ្ឋសភា និងព្រឹទ្ធសភា នៅសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ និង
- អញ្ជើញចូលរួមមីទិញអបអរសាទរខួបលើកទី៧៤ នៃថ្ងៃបង្កើតគណបក្សប្រជាជនកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានគណបក្សប្រជាជនកម្ពុជា នៅវិមាន៧មករា។

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា និង**ឯកឧត្តម អោក បូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញដឹកនាំគណៈប្រតិភូអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមពិធីបុណ្យគម្រប់ខួប៧ថ្ងៃ **លោក មុន្នី មករា** មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅស្រុកគិរីវង់ ខេត្តតាកែវ។

❖ **ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភាបាន៖

- អញ្ជើញចូលរួមអម **ឯកឧត្តម អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា ក្នុងពិធីប្រគល់-ទទួលម៉ាស៊ីនលាងឈាម និងបរិក្ខារពេទ្យ ជូនដល់ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា និង
- អញ្ជើញចូលរួមកិច្ចប្រជុំការងារសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន២លើក។

❖ **ឯកឧត្តម អោក បូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភាបាន៖

- ដឹកនាំគណៈប្រតិភូអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធសព

**លោកព្រឹទ្ធបាលឯក សួន ព៉ាន** ដែលបានពលីនៅក្នុងហេតុការណ៍ផ្ទុះអាវុធរវាងកងទ័ពកម្ពុជា-ថៃ និងបានពាំនាំនូវថវិកាមួយចំនួនរបស់ **ឯកឧត្តម អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា និង**ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា ជូនដល់ក្រុមគ្រួសារសពយោធិនរូបនេះ នៅទីបញ្ជាការកងពលតូចអន្តរាគមន៍លេខ៩ ស្ថិតនៅស្រុកជាំក្សាន្ត ខេត្តព្រះវិហារ និង

- អញ្ជើញចូលរួមកិច្ចប្រជុំការងារសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន២លើក។

❖ **ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភាបាន៖

- អញ្ជើញចូលរួមមីទិញអបអរសាទរខួបលើកទី៤៨ នៃទិវាការចងចាំដំណើរឆ្ពោះទៅការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត នៅតំបន់ប្រវត្តិសាស្រ្តយោធាតេជោកោះថ្ម X១៦ ស្ថិតនៅស្រុកមេមត់ ខេត្តត្បូងឃ្មុំ។
- អញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធ និងពិធីបូជាសពរបស់ **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ម៉ុម ជឹមហ៊ុយ** ទីប្រឹក្សាសម្តេចតេជោប្រធានព្រឹទ្ធសភា និងជាអតីតសមាជិករាជរដ្ឋាភិបាល រដ្ឋសភា និងព្រឹទ្ធសភា នៅសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ និង
- អញ្ជើញចូលរួមកិច្ចប្រជុំការងារសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងពិធីផ្សេងៗ ចំនួន៦លើក។

- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតថ្វាយព្រះពររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ទូលថ្វាយ **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ក្នុងឱកាសដ៏មហានក្ខត្តឫក្សនៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្មាយុគម្រប់ ៨៩ព្រះវស្សា យាងចូល ៩០ព្រះវស្សា។
- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតថ្លែងអំណរព្រះគុណរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ទូលថ្វាយ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា ដែលព្រះអង្គសព្វព្រះរាជហឫទ័យប្រោសព្រះរាជទានព្រះរាជសារកោតសរសើរ **សម្តេចតេជោ** ក្នុងការចុះបំពេញបេសកកម្មលើកទឹកចិត្ត និងសួរសុខទុក្ខវីរកងទ័ព ដែលកំពុងបំពេញបេសកកម្មប្រចាំការនៅសមរភូមិជួរមុខ និងប្រជាជនដែលបានជម្លៀសចេញពីតំបន់ប្រឈម តាមព្រំដែនកម្ពុជា-ថៃ ក្នុងខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារ និងក្នុងការដឹកនាំប្រទេសនាពេលកន្លងមក។
- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតអបអរសាទររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា គោរពជូន៖
    - **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត អ៊ឹម ឈុនលឹម** ដែលត្រូវបាន **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជាសព្វព្រះរាជហឫទ័យត្រាស់បង្គាប់តែងតាំងជា "ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា" និង
    - **ឯកឧត្តម ហ៊ី សោភា** ដែលត្រូវបានកិច្ចប្រជុំពេញអង្គក្រុមប្រឹក្សាធម្មនុញ្ញ បានបោះឆ្នោតជាឯកច្ឆន្ទជ្រើសតាំងជា "ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ" សម្រាប់អាណត្តិ៣ឆ្នាំ លើកទី១០ (២០២៥-២០២៨)។

- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតជូនពររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងឱកាសនៃពិធីចម្រើនជន្មាយុ គោរពជូន៖
    - **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង
    - **លោកជំទាវ មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា។
- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតរំលែកទុក្ខរបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា គោរពជូន៖
    - **លោកជំទាវ សាប៊ី ពិន្លា** ព្រមទាំងក្រុមគ្រួសារ ចំពោះមរណភាពរបស់ **ឯកឧត្តម កិត្តិនីតិកោសលបណ្ឌិត ម៉ុម ជឹមហ៊ុយ** ទីប្រឹក្សាសម្តេចប្រធានព្រឹទ្ធសភា និងជាអតីតសមាជិករាជរដ្ឋាភិបាល រដ្ឋសភា និងព្រឹទ្ធសភា។
    - **សម្តេចមហាមន្ត្រី គុយ សុផល** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង ព្រមទាំងក្រុមគ្រួសារ ចំពោះមរណភាពរបស់ **ឯកឧត្តម សុក ខា** អតីតអនុប្រធានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ។
    - **លោកស្រី អ៊ុក ពង្សបុប្ផា** ព្រមទាំងក្រុមគ្រួសារ ចំពោះមរណភាពរបស់ **លោកព្រឹទ្ធាចារ្យ ក្រមាមាស សាន គឹមស៊ាន** ប្រធានបណ្ឌិត្យសភាល្បុក្កតោកម្ពុជា និងជាអនុប្រធានសហព័ន្ធកីឡាគុនល្បុក្កតោកម្ពុជា និង
    - **លោក ចាន់ វណ្ណៈមុន្នី** ព្រមទាំងក្រុមគ្រួសារ ចំពោះមរណភាពរបស់ **លោក មុន្នី មករា** មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- បានធ្វើបទបង្ហាញស្តីពី រចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងសាវតារបស់ព្រឹទ្ធសភា ជូនសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និងនិស្សិត មកពីសមាគមទំនាក់ទំនងយុវជនកម្ពុជា-ចិន សាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា និងវិទ្យាស្ថានវ៉ាន់ដា សរុបចំនួន២០៦នាក់។
- បានទទួលពាក្យបណ្តឹង ចំនួន៧បណ្តឹង បញ្ជូនពាក្យបណ្តឹងចេញទៅក្រសួង-ស្ថាប័ន និងខេត្តពាក់ព័ន្ធ ចំនួន៩បណ្តឹង តម្កល់ទុកមិនចាត់ការ ចំនួន៣បណ្តឹង កំពុងពិនិត្យសិក្សា ចំនួន២បណ្តឹង ទទួលលិខិតឆ្លើយតបពីការដោះស្រាយពីក្រសួង-ស្ថាប័នពាក់ព័ន្ធ ចំនួន៣បណ្តឹង ធ្វើកំណត់បង្ហាញគោរពរាយការណ៍ជូន **សម្តេចតេជោ** ប្រធានព្រឹទ្ធសភា អំពីការឆ្លើយតបលទ្ធផលដោះស្រាយបណ្តឹង ចំនួន១បណ្តឹង ផ្តល់ព័ត៌មានទៅម្ចាស់បណ្តឹង ចំនួន១២បណ្តឹង ទទួលឯកសារជូនជ្រាបពីក្រសួង-ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការ ចំនួន៣បណ្តឹង។

## ៣-មុខងារសហប្រតិបត្តិការអន្តរជាតិ

- **បានរៀបចំចាត់ចែង និងផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា៖**

❖ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា៖**

- **បដិសណ្ឋារកិច្ចភ្ញៀវជាតិ-អន្តរជាតិ៖** បានអនុញ្ញាតឱ្យភ្ញៀវជាតិ-អន្តរជាតិ ចូលជួបសម្តែងការគួរសម ចំនួន៥លើក រួមមាន៖
    + **បដិសណ្ឋារកិច្ចភ្ញៀវជាតិ៖** បានអនុញ្ញាតឱ្យ **លោកជំទាវកិត្តិបណ្ឌិត អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី និងជាប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី នៅវិមាន៧មករា។

+ **បដិសណ្ឋារកិច្ចភ្ញៀវអន្តរជាតិ៖** បានអនុញ្ញាតឱ្យភ្ញៀវអន្តរជាតិ ចូលជួបសម្តែងការគួរសម ចំនួន៤លើក៖

១/ **ឯកឧត្តម ដាតូ ស្រី ទៀង យីង ស៊ីង** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ សិល្បៈ និងវប្បធម៌ នៃប្រទេសម៉ាឡេស៊ី នៅវិមានព្រឹទ្ធសភា។

២/ **ឯកឧត្តម ង្វៀន តិន គឿង** អនុរដ្ឋមន្ត្រីក្រសួងការពារប្រទេសវៀតណាម និងជាអគ្គសេនាធិការនៃកងទ័ពប្រជាជនវៀតណាម នៅវិមាន៧មករា។

៣/ **ឯកឧត្តម ម៉ូរីស៊ីតា យ៉ាស៊ូណូរី** មេបញ្ជាការកងស្វ័យការពារជើងគោកជប៉ុន នៅវិមានព្រឹទ្ធសភា និង

៤/ **ឯកឧត្តម ហ្វាយយ៉ាស មើស៊ីដ កាហ្សី** ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប្រជាមានិតបង់ក្លាដេស នៅវិមានព្រឹទ្ធសភា។

❖ **ឯកឧត្តម អ៊ុច បូររិទ្ធ អនុប្រធានទី១ព្រឹទ្ធសភា៖**

- **សកម្មភាពដឹកនាំកិច្ចប្រជុំ៖** បានអញ្ជើញដឹកនាំកិច្ចប្រជុំត្រៀមចូលរួមសម័យប្រជុំប្រចាំឆ្នាំលើកទី៥០ នៃសភាប្រើភាសាបារាំង (APF) នៅទីក្រុងប៉ារីសនៃសាធារណរដ្ឋបារាំង។
- **បដិសណ្ឋារកិច្ចភ្ញៀវអន្តរជាតិ៖** បានអនុញ្ញាតឱ្យភ្ញៀវអន្តរជាតិ ចូលជួបសម្តែងការគួរសម នៅសាលពិសេស៣ វិមានព្រឹទ្ធសភា ចំនួន៣លើក រួមមាន៖

១/ **លោក ម៉ា ស្សូវ ចិន** នាយកប្រតិបត្តិសមាគមចិន សម្រាប់ការលើកកម្ពស់លទ្ធកម្មនៃអង្គការសហប្រជាជាតិ និងគណៈកម្មការសេដ្ឋកិច្ចពាណិជ្ជកម្មអាស៊ី-ប៉ាស៊ីហ្វិក។

២/ **លោក លីន ស៊ានយ៉ុន** និងសមាគមនិស្សិតប្រចាំសាធារណរដ្ឋប្រជាមានិតចិន CUGB និង

៣/ **លោក គីម ជុងណាម** ប្រធានមូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ។

❖ **ឯកឧត្តមបណ្ឌិត ឆន់ ខន្ធរ្យនា អនុប្រធានទី២ព្រឹទ្ធសភា** បានអនុញ្ញាតឱ្យ **លោកស្រីបណ្ឌិត វ៉ាជី ឌី អាឌីពូទ្រី** ដែលកំពុងធ្វើការស្រាវជ្រាវនៅសាកលវិទ្យាល័យ Jyvaskyla នៅប្រទេសហ្វាំងឡង់ ចូលជួបសម្តែងការគួរសម និងពិភាក្សាអំពីតួនាទីរបស់សភា ក្នុងការជំរុញការអនុវត្តគោលដៅអភិវឌ្ឍន៍ ប្រកបដោយចីរភាព នៅការិយាល័យរបស់ឯកឧត្តមបណ្ឌិត។

❖ **ឯកឧត្តមបណ្ឌិត ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា បានដឹកនាំសមាជិក សមាជិកាគណៈកម្មការទី៣ព្រឹទ្ធសភា អញ្ជើញចូលរួមកម្មវិធីសមាជអេកូឡូស៊ីអន្តរជាតិនេវស្គីលើកទី១១ Programme of the Eleventh Nevsky Ecological Congress តាមប្រព័ន្ធនិម្មិតពីទីក្រុង Saint Petersburg សហព័ន្ធរុស្ស៊ី ក្រោមប្រធានបទ "អេកូឡូស៊ីនៃតថភាពថ្មី៖ បញ្ហាប្រឈម និងឱកាស" នៅសាលពិសេសកណ្តាល វិមានព្រឹទ្ធសភា។

❖ **ឯកឧត្តមបណ្ឌិត នាង ផាត** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភាបាន៖

- អញ្ជើញចូលរួមពិធីពិសាអាហារពេលល្ងាចជាមួយ **លោក ប៊ីណាដ ហ្វីលីព** ជំនួយការលេខាទីមួយផ្នែកគោលនយោបាយអន្តរជាតិអូស្ត្រាលី នៅភោជនីយដ្ឋាន Malis រាជធានីភ្នំពេញ និង

- អញ្ជើញចូលរួមក្នុងពិធីជួបជុំអតីតនិស្សិតយោធាកម្ពុជា-អូស្ត្រាលី ឆ្នាំ២០២៥ នៅសណ្ឋាគារ Raffles Le Royal រាជធានីភ្នំពេញ។

❖ **ឯកឧត្តមបណ្ឌិត ចែម វីឡា** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភាបាន៖

- អញ្ជើញចូលរួមកិច្ចប្រជុំផ្ទៃក្នុងរបស់សភាសមាជិកអាយប៉ា មុននឹងចូលរួមកិច្ចប្រជុំរួមគ្នារវាងថ្នាក់ដឹកនាំអាយប៉ា និងប្រមុខដឹកនាំអាស៊ាន ដើម្បីពិភាក្សាលើសេចក្តីព្រាងសាររបស់អាយប៉ា ដែលឆ្លុះបញ្ចាំងលើប្រធានបទបរិយាបន្នភាព និងនិរន្តរភាពនៃកិច្ចប្រជុំកំពូលអាស៊ានលើកទី៤៦ ដឹកនាំដោយ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ជាម យៀប** អនុប្រធានទី១រដ្ឋសភា និងជាប្រធានក្រុមជាតិអាយប៉ារបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា នៅវិមានរដ្ឋសភានៃសហព័ន្ធម៉ាឡេស៊ី។
- អញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាការងារជាមួយ **ឯកឧត្តម អាណាតូលី បូរ៉ូវីក** ឯកអគ្គរដ្ឋទូតនៃសហព័ន្ធរុស្ស៊ី ប្រចាំព្រះរាជាណាចក្រកម្ពុជា ស្តីពី "កិច្ចការទូទៅពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការអន្តរសភារវាងប្រទេសទាំងពីរ" នៅសាលប្រជុំគណៈកម្មការទី៥ វិមានព្រឹទ្ធសភា។
- ទទួលជួប **លោកជំទាវ មីលេណា ការីដាដ ហ្សាលឌីវើ ភីជ្រា** ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋគុយបា ប្រចាំព្រះរាជាណាចក្រកម្ពុជា ដើម្បីសម្តែងការគួរសម និងពិភាក្សាការងារ នៅវិមាន៧មករា។
- អញ្ជើញចូលរួមកម្មវិធីសំណេះសំណាលជាមួយគណៈប្រតិភូពាណិជ្ជកម្មកាណាដា ដឹកនាំដោយ **កញ្ញា សារ៉ា វីលសារ៉ា** ប្រធានពាណិជ្ជកម្មកាណាដា និងក្រុមហ៊ុន៨០ទៀតជាមួយនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រាជធានីភ្នំពេញ និង
- ជួបពិសាអាហារជាមួយ **លោក យី ច័ន្ទប្រាថ្នា** នាយកប្រតិបត្តិមជ្ឈមណ្ឌលសភាអាស៊ី (PCAsia) នៅភោជនីយដ្ឋាន YAMATO JAPAN។

❖ **ឯកឧត្តម អ៊ុំ សារឹទ្ធ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា និងជាអនុប្រធានបណ្តាញហ្វ្រង់កូហ្វូនសីលធម៌ និងក្រមសីលធម៌សមាជិកសភា បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍នៃបណ្តាញហ្វ្រង់កូហ្វូនសីលធម៌ និងក្រមសីលធម៌សមាជិកសភា តាមប្រព័ន្ធនិម្មិត ដើម្បីពិភាក្សាកម្មវិធី និងប្រធានបទសម្រាប់មហាសន្និបាតប្រចាំឆ្នាំនៃបណ្តាញហ្វ្រង់កូហ្វូនសីលធម៌ និងក្រមសីលធម៌សមាជិកសភា នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។

❖ **ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ធម្មិកោ** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភា បានយាងចូលរួមមហាសន្និបាតគណៈមេធាវីនៃសាធារណរដ្ឋបារាំង និងធ្វើបទបង្ហាញសង្ខេបស្តីពី ច្បាប់សាធារណរដ្ឋបារាំង និងក្រមរដ្ឋប្បវេណីរបស់កម្ពុជា នៅសាធារណរដ្ឋបារាំង និង

❖ សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចូលរួមជាកិត្តិយសក្នុងកម្មវិធី Gala ដើម្បីផ្តល់អាហារូបករណ៍ដល់យុវជនខ្មែរក្រីក្រសម្រាប់ការសិក្សា ចាប់ពីថ្នាក់បឋមសិក្សារហូតដល់បរិញ្ញាបត្រ នៅសណ្ឋាគារ Raffles Le Royal។

- **សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖**

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញចូលរួមអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ក្នុងជំនួបសម្តែងការគួរសមជាមួយ **ឯកឧត្តម ង្វៀន តិន គឿង** អនុរដ្ឋមន្ត្រីក្រសួងការពារប្រទេសវៀតណាម និងជាអគ្គសេនាធិការនៃកងទ័ពប្រជាជនវៀតណាម នៅវិមាន៧មករា និង

❖ **ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមអម **ឯកឧត្តម អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា ក្នុងជំនួបសម្តែងការគួរសមជាមួយ **លោក លីន ស៊ានយ៉ុន** និងសមាគមនិស្សិតប្រចាំសាធារណរដ្ឋប្រជាមានិតចិន CUGB នៅសាលពិសេស៣ វិមានព្រឹទ្ធសភា។

- បានចាត់ចែងបញ្ជូនសារលិខិតថ្លែងអំណរគុណរបស់ **ឯកឧត្តម ចូហ្សេ រ៉ាមូស អរតា** ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ គោរពជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ចំពោះការគាំទ្រដោយឥតងាករេផ្នែកនយោបាយ និងបច្ចេកទេសអស់រយៈពេលជាច្រើនឆ្នាំកន្លងទៅ រហូតដល់ទីម័រឡេស្តេ ចូលជាសមាជិកផ្លូវការរបស់អាស៊ាន។
- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតអបអរសាទររបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា គោរពជូន **ឯកឧត្តម** Lee Jae-myung ដែលបានជាប់ឆ្នោតជាប្រធានាធិបតីនៃសាធារណរដ្ឋកូរ៉េ និង
- បានសហការ និងទាក់ទងជាមួយស្ថានទូតចិន ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស មូលនិធិចិនដើម្បីអភិវឌ្ឍន៍ជនបទ(CFRD) មជ្ឈមណ្ឌលស្រាវជ្រាវច្បាប់ចិន-អាស៊ាន(CALRC) មជ្ឈមណ្ឌលឯកសារច្បាប់កម្ពុជា សមាគមអ្នកស្រាវជ្រាវវឌ្ឍនភាពកម្ពុជា-ចិន បណ្ណាសារដ្ឋានជាតិ និងក្រសួង-ស្ថាប័ននានា ដើម្បីសម្របសម្រួលកិច្ចសហប្រតិបត្តិការអន្តរជាតិ ការស្នើសុំអាហារូបករណ៍ រៀបចំវគ្គបណ្តុះបណ្តាល ការស្វែងរកភ្ញៀវគរជំនួយ ព្រមទាំងការរៀបចំកម្មវិធីផ្សេងៗ។

## ៤-មុខងារអភិវឌ្ឍន៍ស្ថាប័ន

### ៤.១-សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖

- **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភាបាន៖
  - អញ្ជើញដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែឧសភា និងទិសដៅការងារខែមិថុនា ឆ្នាំ២០២៥ នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។
  - អញ្ជើញដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាវិន័យនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដោយមានការចូលរួមពីថ្នាក់ដឹកនាំក្រុមប្រឹក្សាវិន័យនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅបន្ទប់ប្រជុំឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា និង
  - អញ្ជើញដឹកនាំកិច្ចប្រជុំក្រុមការងារវាយតម្លៃដំឡើងថ្នាក់មន្ត្រីរាជការ ដោយមានការចូលរួមពីថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅបន្ទប់ប្រជុំឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា។

- **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា **ឯកឧត្តម ខេង សិទ្ធិគុណ** និង**ឯកឧត្តម អោក ប៉ូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភាបាន៖
  - អញ្ជើញចូលរួមកិច្ចប្រជុំពិនិត្យវឌ្ឍនភាពដំណើរការសាងសង់អគារថ្មីនៃព្រឹទ្ធសភា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងជាប្រធានគណៈកម្មការសាងសង់អគារថ្មីនៃព្រឹទ្ធសភា នៅទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និង
  - អញ្ជើញអមដំណើរ **ឯកឧត្តម ប្រាក់ សុខុន** ប្រធានគណៈកម្មការសាងសង់អគារថ្មីនៃព្រឹទ្ធសភា ត្រួតពិនិត្យមើលវឌ្ឍនភាពនៃដំណើរការសាងសង់អគារថ្មីនៃព្រឹទ្ធសភា ដោយផ្ទាល់ នៅវិមានព្រឹទ្ធសភា។

### ៤.២-ការងាររដ្ឋបាល និងហិរញ្ញវត្ថុ

- បានបោះពុម្ពផ្សាយអាណត្តិជំពូក ៦០ ៦១ ៦២ និង៦៤ សម្រាប់ត្រីមាសទី៣ បញ្ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- បានស្នើសុំបុរេប្រទានថវិកា និងឥណទានថវិកាបន្ថែម ចំនួន២បុរេប្រទាន សម្រាប់ចំណាយរៀបចំបុណ្យសពជូនសមាជិកព្រឹទ្ធសភា ចំនួន២រូប និងបេសកកម្មក្រៅប្រទេសរបស់ប្រតិភូព្រឹទ្ធសភា។
- បានទូទាត់បុរេប្រទានថវិកា ចំនួន៤បុរេប្រទាន សម្រាប់ទិញរថយន្តថ្មី ជូនឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា និងការចុះបេសកកម្មក្រៅប្រទេសរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា។
- បានបង្វែរប្រាក់បៀវត្ស ប្រាក់បំណាច់ ប្រចាំខែមិថុនា ឆ្នាំ២០២៥ និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាជិក សមាជិកាព្រឹទ្ធសភា សមាជិក សមាជិកាព្រឹទ្ធសភាចូលនិវត្តន៍ និងថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា និវត្តជន មន្ត្រីនគរបាលសន្តិសុខ ជំនួយការផ្ទាល់ អ្នកបើកបររថយន្ត តាមរយៈប្រព័ន្ធធនាគារអេស៊ីលីដា។
- បានបង្វែរប្រាក់ប្រមុខរដ្ឋស្តីទី ប្រាក់សង្គមកិច្ចថ្នាក់ដឹកនាំព្រឹទ្ធសភា ប្រាក់ឧបត្ថម្ភពិនិត្យ និងព្យាបាលជំងឺមន្ត្រីរាជការ ប្រាក់៧%នៃប្រាក់បៀវត្សមន្ត្រីរាជការបង់ចូលបេឡាសោធននិវត្តន៍ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងប្រាក់ឧបត្ថម្ភមូលនិធិសង្គមកិច្ចមន្ត្រីរាជការ ប្រចាំខែមិថុនា ឆ្នាំ២០២៥ តាមរយៈប្រព័ន្ធធនាគារអេស៊ីលីដា។
- បានបង្វែរប្រាក់វិភាគទានជូនអង្គភាពបេឡាជាតិសន្តិសុខសង្គម (ប.ស.ស) របស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមិថុនា ឆ្នាំ២០២៥។
- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន១២៥សំណើ ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗ ចំនួន១៣៤សំណើ។
- បានដោះស្រាយសំណើផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ ប្រេងឥន្ធនៈ សម្ភារៈអនាម័យ សម្ភារៈការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំ សិក្ខាសាលា និងកម្មវិធីផ្សេងៗ ចំនួន៣៦សំណើ។
- បានថតចម្លងឯកសារ ចំនួន៤,៩៨៨ច្បាប់ និងចងក្រងធ្វើជាសៀវភៅ ចំនួន៥ក្បាល ប្រើប្រាស់ក្រដាសអស់ ចំនួន១៩៣,៥១៥សន្លឹក។

- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្ម នៅតាមបណ្តាភូមិភាគទាំង៨ ចំនួន ៧០លើក ស្មើនឹង២០៦នាក់។
- បានរៀបចំបោសសម្អាត តុបតែងលម្អសាល ព្រមទាំងផ្តល់សេវាបម្រើភេសជ្ជៈ ក្នុងកិច្ចប្រជុំ និងកម្មវិធីផ្សេងៗ ចំនួន៣៨លើក។
- បានទទួលលិខិតចូល ចំនួន៥៧២ច្បាប់ និងបញ្ជូនលិខិតចេញទៅក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ចំនួន៣៨៧ច្បាប់។
- បានធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន២៤ច្បាប់ ស្មើនឹង៦៨នាក់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិក សមាជិកាព្រឹទ្ធសភា ចំនួន៩ច្បាប់។
- បានចុះសួរសុខទុក្ខមន្ត្រីរាជការលំហែមាតុភាព និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅរាជធានីភ្នំពេញ និងខេត្តតាកែវ ចំនួន១០នាក់។
- ការងារកែលម្អសួនច្បារ និងបរិស្ថានក្នុងបរិវេណព្រឹទ្ធសភា រួមមាន៖
    - បានកាត់តម្រឹមស្មៅ មែកឈើ និងផ្កានានា ចំនួន១៨លើក។
    - បានដាំដើមជ្រៃភ្នំ និងដើមឫស្សី ចំនួន៨៨គុម្ព និង
    - បានសម្អាតអនាម័យតាមអគារធ្វើការ និងក្នុងបរិវេណព្រឹទ្ធសភាជាប្រចាំ។
- បានសម្របសម្រួលការរៀបចំគូរប្លង់រចនាទេសភាពសួនច្បារស្រះត្រី និងសួនច្បារសាលពិសេស វិមានព្រឹទ្ធសភា។
- បានធ្វើបញ្ជីស្ថិតិមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមិថុនា មានចំនួន៧១៥នាក់ (ស្រី២៨៩នាក់) ក្នុងនោះ
    - មន្ត្រីរាជការស្ថិតក្នុងភាពទំនេរដោយគ្មានបៀវត្ស ចំនួន១២នាក់។
    - មន្ត្រីរាជការស្ថិតនៅក្រៅក្របខ័ណ្ឌដើម ចំនួន៥នាក់។
    - មន្ត្រីរាជការមានមុខតំណែងគ្រប់គ្រង ចំនួន៤៩២នាក់ និង
    - បុគ្គលិកជាប់កិច្ចសន្យា ចំនួន៨៧នាក់ (ស្រី៣៥នាក់)។
- បានធ្វើសេចក្តីសម្រេច ចំនួន៦ច្បាប់ និងលិខិតបង្គាប់ការ ចំនួន២ច្បាប់។
- បានធ្វើតារាងបញ្ជាក់ប្រាក់បៀវត្ស ប្រាក់បំណាច់ផ្សេងៗ លិខិតផ្តត់ផ្គង់ និងវិញ្ញាបនបត្របញ្ជាក់រយៈពេលបំពេញការងាររដ្ឋ ចំនួន៤ច្បាប់។
- បានធ្វើបញ្ជីរាយនាមមន្ត្រីរាជការស្នើសុំប្រាក់វិភាជន៍គ្រួសារ (ប្រពន្ធ-កូន) ប្រចាំខែមិថុនា ឆ្នាំ២០២៥។
- បានសហការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រៀបចំធ្វើបច្ចុប្បន្នភាពប័ណ្ណសមាជិកបេឡាជាតិសន្តិសុខសង្គម (ប.ស.ស) ជូនមន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។
- បានធ្វើបច្ចុប្បន្នភាព និងរៀបចំសេចក្តីព្រាងកម្រងសំណួរសម្រាប់សិក្សាពីតម្រូវការជំនាញតាម Google Form ដើម្បីត្រៀមធ្វើផែនការបណ្តុះបណ្តាលឆ្នាំ២០២៦។

- ការងារសាងសង់សំណង់ថ្មីៗ ជួសជុលកែលម្អអគារ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ក្នុងបរិវេណវិមានព្រឹទ្ធសភា រួមមាន៖
    - បានរៀបចំបន្ទប់ការិយាល័យជូន **ឯកឧត្តម សាន សាង** ទីប្រឹក្សាសម្ដេចតេជោប្រធានព្រឹទ្ធសភា។
    - បានរៀបចំបន្ទប់ការិយាល័យក្រុមការងារព័ត៌មាន សម្ដេចតេជោប្រធានព្រឹទ្ធសភា និងក្រុមការងារបច្ចេកទេសនៃទូរទស្សន៍ជាតិកម្ពុជា នៅក្រោមអគារក្រហម និងជូនមេបញ្ជាការអង្គរក្សការពារព្រឹទ្ធសភា។
    - បានជួសជុលផ្លាស់ប្ដូរការ៉ូបាត ដំឡើងសំណាញ់ទទឹក ជួសជុល និងលាបថ្នាំពិដាន Coffee Counter នៅសាលពិសេស៣។
    - បានបំពាក់កញ្ចក់សុវត្ថិភាពផ្លូវកែង និងស្លាកសញ្ញាបន្ថយល្បឿន ចំនួន៧ស្លាក និង
    - បានចាក់គម្របលូ នៅក្រោយអគារជប៉ុន។
- បានជួសជុលកែលម្អហេដ្ឋារចនាសម្ព័ន្ធអគារ បណ្ដាញទឹក បណ្ដាញអគ្គិសនី ត្រួតពិនិត្យដំណើរយន្តកំចាត់សត្វកណ្ដៀរ រៀបចំ និងផ្លាស់ប្ដូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារិម ប្រមូលសម្ភារៈខូច បិទលេខកូដសម្ភារៈសារពើភ័ណ្ឌ និងបំពាក់សម្ភារៈការិយាល័យជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀតក្នុងបរិវេណព្រឹទ្ធសភា ចំនួន៧៣គ្រឿង/លើក។
- បានស្រាវជ្រាវ និងរៀបចំចងក្រងសៀវភៅអំពីការវិវឌ្ឍនៃការប្រើប្រាស់អគារមួយចំនួន នៅវិមានព្រឹទ្ធសភា។
- បានសម្របសម្រួលការងារការដ្ឋាន និងបានរៀបចំរបាយការណ៍វឌ្ឍនភាពការងារសាងសង់អគារថ្មីនៃព្រឹទ្ធសភា រៀងរាល់ ២សប្ដាហ៍ម្ដង គោរពជូនថ្នាក់ដឹកនាំព្រឹទ្ធសភា។
- បានធ្វើស្លាកលេខរថយន្តព្រឹទ្ធសភាថ្មី ជូនសមាជិកព្រឹទ្ធសភា។
- បានធ្វើរបាយការណ៍ស្ដីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា ប្រចាំខែមិថុនា និងប្រចាំឆមាសទី១ ឆ្នាំ២០២៥ ទូលថ្វាយ **ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា។
- បានធ្វើរបាយការណ៍ស្ដីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមិថុនា និងប្រចាំឆមាសទី១ ឆ្នាំ២០២៥ ព្រមទាំងបានផ្សព្វផ្សាយលើគេហទំព័រព្រឹទ្ធសភា និងផ្ញើជូនក្រសួង-ស្ថាប័នពាក់ព័ន្ធនានា និង
- បានធ្វើបទបង្ហាញ និងរបាយការណ៍ស្ដីពី ការប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមិថុនា ឆ្នាំ២០២៥។

### ៤.៣-ការងារសេវាច្បាប់៖

- បានទទួលអនុក្រឹត្យ ប្រកាស សេចក្ដីសម្រេច សារាចរ និងលិខិតផ្សេងៗ ចំនួន៥២ច្បាប់ ពីក្រសួង និងស្ថាប័ននានា។
- បានទទួលសេចក្ដីព្រាងច្បាប់ពីរដ្ឋសភា ចំនួន២៦ច្បាប់ ព្រមទាំងបានថ្វាយ និងចែកគ្រប់សមាជិក សមាជិកាព្រឹទ្ធសភា។

- បានរៀបចំឯកសារជំនួយស្មារតីក្នុងកិច្ចដំណើរការនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងសម័យប្រជុំលើកទី៣ព្រឹទ្ធសភា នីតិកាលទី៥ ជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ចំនួន៥លើក។
- បានរៀបចំឯកសារជំនួយស្មារតីជូនលេខាធិការសម័យប្រជុំលើកទី៣ព្រឹទ្ធសភា នីតិកាលទី៥ ចំនួន ២លើក។
- បានរៀបចំឯកសារជំនួយស្មារតីជូនថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា រាយការណ៍ជូនអង្គប្រជុំ ចំនួន៣លើក។
- បានរៀបចំនីតិវិធីបោះឆ្នោតជ្រើសរើសបំពេញសមាជិកគណៈកម្មការទី៤ និងគណៈកម្មការទី៨ ព្រឹទ្ធសភា នីតិកាលទី៥។
- បានធ្វើកំណត់ហេតុពិស្តារ និងកំណត់ហេតុសង្ខេបនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា សម័យប្រជុំព្រឹទ្ធសភា នីតិកាលទី៥ និងកិច្ចប្រជុំគណៈកម្មការពិសេស ចំនួន៧លើក។
- បានធ្វើបច្ចុប្បន្នភាព ប្រមូលផ្តុំចងក្រងឯកសារនានា រួមមាន៖
    - សម្រង់សង្ខេបសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់ ដែលព្រឹទ្ធសភាបានពិនិត្យ ហើយឱ្យយោបល់ តាមនីតិកាលនីមួយៗ។
    - សម្រង់លទ្ធផលសង្ខេបនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងសម័យប្រជុំព្រឹទ្ធសភា នីតិកាលទី៥។
    - បញ្ជីដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងសម័យប្រជុំព្រឹទ្ធសភា នីតិកាលទី៥ និង
    - បញ្ជីសេចក្តីព្រាងច្បាប់ ដែលព្រឹទ្ធសភាបានពិនិត្យ ហើយឱ្យយោបល់ តាមនីតិកាលនីមួយៗ។
- បានផ្តល់សេវារដ្ឋបាល បច្ចេកទេស ព័ត៌មាន ពិធីការ ទំនាក់ទំនងការងារ ធ្វើរបាយការណ៍ និងរៀបចំកំណត់បង្ហាញ ឯកសារផ្សេងៗ ជូនថ្នាក់ដឹកនាំព្រឹទ្ធសភា សមាជិក សមាជិកាគណៈកម្មការទាំង១០ និងក្រុមនានារបស់ព្រឹទ្ធសភា អញ្ជើញចុះបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា ព្រមទាំងក្នុងកិច្ចប្រជុំ និងកម្មវិធីផ្សេងៗ ចំនួន២៨៤លើក និង
- បានសម្រួលបញ្ជូនឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុល ទទួលការតែងតាំងថ្មីទៅអង្គភាពប្រឆាំងអំពើពុករលួយ ចំនួន២នាក់។

## ៤.៤-ការងារស្រាវជ្រាវ៖

- បានរៀបចំឯកសារស្រាវជ្រាវ និងឯកសារជំនួយស្មារតីលើសេចក្តីព្រាងច្បាប់ ចំនួន២៦ច្បាប់ រួមមាន៖
    - សេចក្តីព្រាងច្បាប់ស្តីពី ជលផល។
    - សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុនអភិវឌ្ឍន៍នានា ចំនួន២៤ច្បាប់ និង
    - សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភា។
- បានសិក្សាស្រាវជ្រាវ និងតាមដានវឌ្ឍនភាពនៃការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយពាក់ព័ន្ធតាមវិស័យនានា។
- បានរៀបចំឯកសារស្រាវជ្រាវ និងធ្វើបទបង្ហាញលើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រម

លើការជានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុនអភិវឌ្ឍន៍នានា ចំនួន២៤ច្បាប់ និងសេចក្តីព្រាងច្បាប់ស្តីពី ជលផល ជូនសមាជិកក្រុមទី១ និងទី៤នៃក្រុមសមាជិកព្រឹទ្ធសភា។

- បានសិក្សាស្រាវជ្រាវ បកប្រែរដ្ឋធម្មនុញ្ញ និងបទបញ្ជាផ្ទៃក្នុងស្តីពី ក្រមសីលធម៌សភា សមាជិកសភា និងព័ត៌មានទូទៅ របស់រដ្ឋសភានៃសាធារណរដ្ឋកូរ៉េ។
- បន្តចងក្រងទិន្នន័យលិខិតបទដ្ឋានគតិយុត្តតាមវិស័យរបស់គណៈកម្មការនានា។
- បានផលិតព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច ប្រចាំសប្តាហ៍ ខែមិថុនា ឆ្នាំ២០២៥ ចំនួន៤ច្បាប់។
- បានបកប្រែ និងសង្ខេបព័ត៌មានសភាបញ្ចូលក្នុងសម្រង់សង្ខេបព័ត៌មានសំខាន់ៗប្រចាំថ្ងៃ ចំនួន ១៩៦ព័ត៌មាន និង
- បានបញ្ចូលព័ត៌មាន និងចាត់ថ្នាក់ទៅតាមវិស័យច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត (រាជកិច្ចពីលេខ ២៣-២៧ ឆ្នាំ២០២៤)។

**៤.៤-ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ**

- បានផលិត និងផ្សព្វផ្សាយខ្សែវីដេអូព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងាររបស់ព្រឹទ្ធសភា ចំនួន១២លើក។
- បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងាររបស់ព្រឹទ្ធសភា និង អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងបណ្តាញសង្គម ចំនួន១,២១០លើក។
- បានបញ្ចូលព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងាររបស់ព្រឹទ្ធសភា និង អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា លើគេហទំព័រព្រឹទ្ធសភា ចំនួន៣៦៤សកម្មភាព។
- បានអញ្ជើញអ្នកសារព័ត៌មាន ចូលយកព័ត៌មានព្រឹទ្ធសភា និងពិធីផ្សេងៗ ចំនួន១៦លើក។
- បានតាំងពិព័រណ៍រូបភាពសកម្មភាពរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភានៅខ្លោងទ្វារខាងមុខព្រឹទ្ធសភា ចំនួន ១៥លើក។
- បានរៀបចំផលិតទស្សនាវដ្តីព្រឹទ្ធសភា ប្រចាំខែមិថុនា ឆ្នាំ២០២៥។
- បានសិក្សាស្រាវជ្រាវ ចងក្រងព្រឹត្តិបត្រស្តីពី បច្ចេកវិទ្យាព័ត៌មាន ចំនួន៤៨ចំណងជើង។
- បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធណេតវើក អ៊ីនធឺណែត ពង្រឹងពង្រីកការផ្គត់ផ្គង់ ថែទាំ និង ជួសជុលឧបករណ៍ សម្ភារៈ បរិក្ខារបច្ចេកទេស ព្រមទាំងដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹង ជំនាញបច្ចេកវិទ្យាព័ត៌មាន ចំនួន៦២គ្រឿង/លើក។
- បានរៀបចំប្រព័ន្ធស្ទូឌីយ៉ូ ប្រព័ន្ធកាមេរ៉ា ប្រព័ន្ធប្រជុំនិម្មិត ព្រមទាំងបានរចនាផ្ទាំង Backdrop Background និងបញ្ចាំងផ្ទាំង LED ក្នុងកិច្ចប្រជុំ ជំនួបសម្តែងការគួរសម និងពិភាក្សាការងារ ជាមួយភ្ញៀវជាតិ-អន្តរជាតិ និងកម្មវិធីផ្សេងៗ ចំនួន៣៥លើក។
- បានទទួលឯកសារ សៀវភៅច្បាប់ ទស្សនាវដ្តី ព្រឹត្តិបត្រ និងសៀវភៅជំនាញផ្សេងៗ ចំនួន ២៣ក្បាល ព្រមទាំងបានចុះបញ្ជីសៀវភៅ បោះត្រាបិទប័ណ្ណខ្ចី និងសងសៀវភៅ ចំនួន១៨ក្បាល។

- បានផ្សព្វផ្សាយឯកសាររបស់ព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឯកសារច្បាប់ ឯកសារជំនាញផ្សេងៗ និងសៀវភៅជា E-Book តាមគេហទំព័រ www.elibrary.senate.gov.kh ចំនួន ៧,៦៧២ក្បាល ដែលមានសាធារណជនចូលអាន ចំនួន១,០២៧នាក់ (ដោយគិតត្រឹមខែមិថុនា ឆ្នាំ២០២៥) និង
- បានទទួលឯកសារពីអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងបានរៀបចំចាត់ចែងតម្កល់រក្សាទុកឯកសារនៅបណ្ណសារដ្ឋាន ដោយបានរៀបចំសៀវភៅព្រឹត្តិបត្រព្រឹទ្ធសភា(ស្ទួន) ឆ្នាំ២០១៣ ចំនួន៦៤៨ក្បាល ត្រួតពិនិត្យបញ្ចូលមាតិកាលិខិត និងមាតិកាសំណុំលិខិតទៅក្នុងប្រព័ន្ធកុំព្យូទ័រ ចំនួន២២សំណុំ។

## ៤.៦-ការងារពិធីការ និងទំនាក់ទំនងអន្តរជាតិ៖

- បានរៀបចំចាត់ចែង និងសម្របសម្រួលជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ ជំនួបសម្ដែងការគួរសម ពិភាក្សាការងារ និងពិធីផ្សេងៗ ចំនួន៦១លើក។
- បានរៀបចំសារលិខិតថ្វាយព្រះពរ លិខិតអបអរសាទរ និងលិខិតរំលែកទុក្ខ របស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ទូលថ្វាយ **សម្ដេចព្រះមហាក្សត្រី** ព្រះវររាជមាតាជាតិខ្មែរ ព្រមទាំងជូនឥស្សរជនជាន់ខ្ពស់ និងថ្នាក់ដឹកនាំតាមក្រសួង-ស្ថាប័ននានា ចំនួន៧លិខិត។
- បានរៀបចំកំណត់បង្ហាញ និងឯកសារផ្សេងៗ ជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន១៩ច្បាប់/លើក។
- បានផលិត និងផ្សព្វផ្សាយ "ព្រឹត្តិបត្រព័ត៌មានកិច្ចការអន្តរជាតិ ប្រចាំខែមិថុនា ឆ្នាំ២០២៥" ចំនួន ១ច្បាប់។
- បានតាមដាន និងចងក្រងសេចក្ដីប្រកាសព័ត៌មាន និងសេចក្ដីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចំនួន៦ច្បាប់។
- បានរៀបចំបែបបទស្នើសុំលិខិតឆ្លងដែនផ្លូវការជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងជំនួយការខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា ចំនួន២រូប និង
- បានតុបតែងលម្អបំភ្លឺភ្លើងពណ៌នៅខាងមុខស្ថាប័នព្រឹទ្ធសភា និងចងបដា ពាក្យស្លោក ក្នុងឱកាសនៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម **សម្ដេចព្រះមហាក្សត្រី** ព្រះវររាជមាតាជាតិខ្មែរ។

## ៤.៧-ការងារអគ្គាធិការដ្ឋាន៖

- បានប្រជុំពិភាក្សាការងារអំពីលទ្ធផលការងារសង្គមកិច្ច និងការផ្ដល់សេវាជាមួយអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមិថុនា ឆ្នាំ២០២៥ ចំនួន២២លើក។
- បានប្រមូល និងរៀបចំរបាយការណ៍ជាមួយនាយកដ្ឋានផែនការ និងសរុប នាយកដ្ឋានគ្រប់គ្រងបុគ្គលិក នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស និងបណ្ណសារដ្ឋានស្ដីពី ការអនុវត្តផែនការការងារ និងគោលនយោបាយនានា របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- បានរៀបចំរបាយការណ៍ស្ដីពី លទ្ធផលការងាររបស់នាយកដ្ឋានត្រួតពិនិត្យការងារសង្គមកិច្ច និងការផ្ដល់សេវា ប្រចាំខែមិថុនា ឆ្នាំ២០២៥។

- បានចុះត្រួតពិនិត្យវត្តមានដាក់ស្តែងតាមនាយកដ្ឋាននានា ប្រចាំខែមិថុនា ឆ្នាំ២០២៥ ចំនួន២លើក ដើម្បីផ្ទៀងផ្ទាត់បញ្ជីវត្តមាន ដែលនាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបញ្ជូនមកអគ្គាធិការដ្ឋានប្រចាំថ្ងៃ។
- បានបូកសរុប និងធ្វើរបាយការណ៍សម្រង់វត្តមាន ប្រចាំថ្ងៃ ចំនួន៤០លើក ប្រចាំសប្តាហ៍ ចំនួន៤លើក និងប្រចាំខែមិថុនា ឆ្នាំ២០២៥ ដែលគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបញ្ជូនមកអគ្គាធិការដ្ឋានប្រចាំថ្ងៃ។
- បានចុះត្រួតពិនិត្យ និងធ្វើរបាយការណ៍ស្តីពី បរិស្ថាន អនាម័យ ការខូចខាតសម្ភារៈតាមអគារ និងសណ្តាប់ធ្នាប់នៃការចតយានយន្តក្នុងបរិវេណព្រឹទ្ធសភា និង
- បានធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះមន្ត្រីរាជការតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

## II-ទិសដៅការងារខែកក្កដា ឆ្នាំ២០២៥

### ១- មុខងារនីតិកម្ម

- ត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ប្រជុំពេញអង្គព្រឹទ្ធសភា និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៥ និង
- ត្រៀមប្រជុំផែនការថវិការបស់ព្រឹទ្ធសភា ឆ្នាំ២០២៦ ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

### ២-មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា

- ត្រៀមសហការ និងសម្របសម្រួលការងារជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ជួបសវនាការជាមួយក្រសួង-ស្ថាប័ន អាជ្ញាធរថ្នាក់ក្រោមជាតិ និងចុះបេសកកម្ម ដើម្បីតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា និង
- ត្រៀមផ្តល់សេវាជូនគណៈកម្មការទី៧ព្រឹទ្ធសភា អញ្ជើញចុះសិក្សាឈ្វេងយល់អំពីវឌ្ឍនភាពការងារ បញ្ហាប្រឈម វិធានការដោះស្រាយ ចក្ខុវិស័យរបស់រដ្ឋបាលខេត្ត និងមន្ទីរ ជំនាញពាក់ព័ន្ធវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ នៅខេត្តកំពង់ស្ពឺ និងខេត្តកោះកុង។

### ៣- មុខងារតំណាង

- ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ ពិភាក្សាការងារជាមួយអាជ្ញាធរដែនដី ពិនិត្យវឌ្ឍនភាពនៃការអភិវឌ្ឍ នៅថ្នាក់ក្រោមជាតិ ចូលរួមសិក្ខាសាលា វេទិកា កិច្ចប្រជុំនានា និងពិធីផ្លូវការផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា។
- ត្រៀមផ្តល់សេវាជូនសមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះបំពេញការងារនៅមូលដ្ឋាន រួមមាន៖
    - ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ទី៤ ទី៥ និងទី៧ អញ្ជើញជួបសំណេះសំណាល ជាមួយអង្គបោះឆ្នោត និងអ្នកពាក់ព័ន្ធ ព្រមទាំងចូលរួមដោះស្រាយ និងនាំយកយោបល់ សំណូមពរ ឬបញ្ហានានា ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នៅខេត្តកំពង់ចាម ខេត្តសៀមរាប ខេត្តតាកែវ និងខេត្តកំពង់ស្ពឺ និង
    - ក្រុមសមាជិកាព្រឹទ្ធសភា អញ្ជើញជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ជាស្ត្រី ដើម្បីឈ្វេងយល់ពីតម្រូវការ បញ្ហាប្រឈម និងសំណូមពររបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ជាស្ត្រី នៅខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តព្រះសីហនុ និងខេត្តកោះកុង។

- ត្រៀមទទួលដំណើរទស្សនកិច្ចរបស់សាធារណជន សិស្ស និស្សិត ដើម្បីសិក្សាឈ្វេងយល់អំពីរចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់ព្រឹទ្ធសភា។

## ៤- មុខងារសហប្រតិបត្តិការអន្តរជាតិ

- ត្រៀមផ្តល់សេវាចាំបាច់បម្រើការងារការទូតសភា ការងារសហប្រតិបត្តិការតំបន់ និងអន្តរជាតិ ការចូលរួមមហាសន្និបាត សិក្ខាសាលា វេទិកា កម្មវិធីជំនួប កម្មវិធីផ្លូវការ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូនានា។
- ត្រៀមរៀបចំជូនគណៈប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភា៖
    - អញ្ជើញចូលរួមសន្និសីទប្រធានសភាពិភពលោកលើកទី៦ និងកិច្ចប្រជុំកំពូលលើកទី១៥ នៃប្រធានសភាជាស្ត្រី នៅប្រទេសស្វីស។
    - អញ្ជើញចូលរួមមហាសន្និបាតសហភាពអន្តរសភាលើកទី១៥១ (IPU-151) និងមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៦ (AIPA-46)។
    - អញ្ជើញចូលរួមកិច្ចប្រជុំក្រុមអ្នកនយោបាយអន្តរសភាអាស៊ានលើកទី១៦ (The 16th AIPA Caucus) នៅរាជធានីភ្នំពេញ។
- បន្តត្រៀមស្រាវជ្រាវ បកប្រែ និងរៀបចំឯកសារជំនួយស្មារតី សុន្ទរកថាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបជាមួយភ្ញៀវអន្តរជាតិក្នុងជំនួបសវនាការ កិច្ចប្រជុំ និងទស្សនកិច្ចនានា។

## ៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន

- បន្តអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនានារួមមាន ការសាងសង់អគារថ្មី ការជួសជុល ថែទាំ កែលម្អបរិស្ថានអនាម័យ សួនច្បារ ប្រព័ន្ធអគ្គិសនី ប្រព័ន្ធទឹក ប្រព័ន្ធលូ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងប្រព័ន្ធសន្តិសុខផ្ទៃក្នុងព្រឹទ្ធសភា ប្រកបដោយសុខសុវត្ថិភាព។
- បន្តផ្តល់សេវាផ្គត់ផ្គង់សម្ភារៈ ថវិកា មធ្យោបាយដឹកជញ្ជូន ទំនាក់ទំនងជាមួយអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងសេវាសំខាន់ៗផ្សេងទៀតជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បំពេញមុខងាររបស់ខ្លួនឱ្យបានទាន់ពេលវេលា និងល្អប្រសើរ និង
- បន្តចុះសួរសុខទុក្ខមន្ត្រីរាជការលំហែមាតុភាព និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

## III-សេចក្តីសន្និដ្ឋាន

ខែមិថុនា ឆ្នាំ២០២៥នេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកា គណៈកម្មការ យន្តការនានា របស់ព្រឹទ្ធសភា បំពេញមុខងារនីតិកម្ម មុខងារតំណាង និងមុខងារកិច្ចសហប្រតិបត្តិការអន្តរជាតិ ដោយបានរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងសម័យប្រជុំលើកទី៣ព្រឹទ្ធសភា នីតិកាលទី៥ ចុះបំពេញការងារលើមុខងារតំណាង នៅតាមភូមិភាគទាំង៨ ដើម្បីជួបប្រាស្រ័យទាក់ទងជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ ចូលរួមដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា ជាពិសេសការលើកកម្ពស់គណនេយ្យភាពជាមួយអង្គបោះឆ្នោត ប្រព្រឹត្តទៅដោយរលូន។

ចំពោះការងារកិច្ចសហប្រតិបត្តិការអន្តរជាតិ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានយកចិត្តទុកដាក់ខ្ពស់ក្នុងការផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការបំពេញមុខងារការទូតសភា

ការជួបពិភាក្សាការងារជាមួយភ្ញៀវជាតិ-អន្តរជាតិ និងដំណើរបេសកកម្មក្រៅប្រទេស ដោយសម្រេចបាននូវលទ្ធផលដ៏ល្អប្រសើរ។

ស្ថិតក្នុងបរិការណ៍នៃកិច្ចការពារបូរណភាពទឹកដី ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានរួមចំណែកយ៉ាងសស្រាក់សស្រាំជាមួយរាជរដ្ឋាភិបាល អញ្ជើញចុះសួរសុខទុក្ខ និងផ្តល់ការឧបត្ថម្ភជ្រោមជ្រែងជូនកងទ័ពជួរមុខឈរជើងការពារតាមបណ្តោយខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ គ្រួសារកងទ័ព និងប្រជាជន ក្នុងស្មារតីរួបរួមជាតិតែមួយ។

ថ្ងៃសុក្រ ៤កើត ខែ អស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៥

**អគ្គលេខាធិការ**

**ឡាយ សំគុល**